01120371



**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **ឯកសារបកប្រែ**<br>TRANSLATION/TRADUCTION<br>ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2015, 16:00<br>CMS/CFO: Sann Rada | | |

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់**/Confidential

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំឲ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ ចំពោះសំណើរបស់គាត់ សុំឲ្យទុកជាមោឃៈនូវដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ការឆ្លើយតបរបស់គាត់ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលតបទៅនឹងសំណើរបស់ មាស មុត សុំឲ្យទុកជាមោឃៈនូវដីកាបង្គាប់ឲ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ និង សំណើបន្ទាន់របស់គាត់សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ និង សុំឲ្យចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈ ចំពោះសំណើសុំការពិចារណាទាក់ទងទាំងអស់ដែលនឹងដាក់នាពេលខាងមុខ**

---

| **<u>ដាក់ដោយ៖</u>** | **<u>ផ្ញើជូន៖</u>** |
|---|---|
| **សហមេធាវី៖** | **សហចៅក្រមស៊ើបអង្កេត៖** |
| អាង ឧត្តម | ចៅក្រម យូ ប៊ុនឡេង |
| Michael G. KARNAVAS | ចៅក្រម Mark B. HARMON |

01120372

D142

០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

សំណើរបស់ មាស មុត សុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ នូវសំណើសុំការពិចារណាជាច្រើន ដែលទាក់ទងនឹងឯកសារនានាដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈនាពេលថ្មីៗនេះ

Original EN: 01111664-01111669

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ("វិធាន") តាមរយៈនេះ ស្នើសុំថា *សំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤*[1] *ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតបទៅនឹងសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤*[2] *ដីកាបង្គាប់ឱ្យនាំខ្លួន* ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥[3] និង *សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ* ដោយកំបាំងមុខ[4] ត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ។ គាត់ស្នើសុំបន្ថែមទៀតថា រាល់សំណើសុំការពិចារណាទាក់ទងទាំងអស់ ដែលនឹងមាននាពេលខាងមុខ ត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈ[5]។ សំណើនេះត្រូវធ្វើឡើងជាចាំបាច់ ដើម្បី

---

[1] សំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D130។

[2] ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតបទៅនឹងសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ D130/2។

[3] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2។

[4] សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2/1។

[5] ដូចជា ការឆ្លើយតបនាពេលខាងមុខរបស់លោក មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចម្លើយនាពេលខាងមុខរបស់លោក មាស មុត ដែលតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ* និងការឆ្លើយតបខាងពេលខាងមុខរបស់លោក មាស មុត ទៅនឹងចម្លើយនាពេលខាងមុខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតប

ជាប្រយោជន៍នៃតម្លាភាព និង ទប់ស្កាត់ការផ្តល់ព័ត៌មានខុស។ មានសេចក្តីរាយការណ៍ព័ត៌មានថ្មីៗនេះអំពី ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលត្រូវបានចេញប្រឆាំងនឹងលោក មាស មុត។ នៅក្នុងប្រយោជន៍យុត្តិធម៌ និង ដើម្បីឱ្យសាធារណជនអាចយល់ដឹងអំពីបរិបទនៃឯកសារ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញនាពេលថ្មីៗនេះ ឱ្យបានពេញលេញ និង ត្រឹមត្រូវ សំណើសុំការពិចារណាខាងលើ ត្រូវចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសារធារណៈ។ មេធាវីការពារក្តីស្នើសុំដាក់សំណើនេះជាភាសាអង់គ្លេសសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ ដោយពិចារណាទៅលើការពន្យារពេលនានាដែលអង្គភាពបកប្រែភាសាកំពុងប្រឈមមុខនាពេលបច្ចុប្បន្ននេះ[6]។

## I. **សាច់សារ**

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ក.ស.ព. បានផ្តួចផ្តើមការស៊ើបសង្កេតតាមផ្លូវតុលាការទៅលើលោក មាស មុត ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ របស់ ក.ស.ព. ពាក់ព័ន្ធនឹងកងទ័ពបដិវត្តន៍កម្ពុជា[7]។

២. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត Harmon បានសម្រេចដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដោយផ្តល់សិទ្ធិឱ្យគាត់ចូលពិនិត្យមើលសំណុំរឿង និង ចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ[8]។

៣. នៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើមួយដែលស្នើថា រាល់សំណើសុំការពិចារណាទាំងអស់របស់ខ្លួនដែលដាក់ទៅ ក.ស.ច.ស. គួរត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ ("សំណើសុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ")[9]។ នៅថ្ងៃដដែលនោះ

---

ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ*ដោយកំបាំងមុខ*។

[6] *សូមមើល* សារអេឡិចត្រូនិកពីអង្គភាពបកប្រែភាសាផ្ញើជូនមេធាវីការពារក្តី ដែលមានចំណងជើងថា៖ "កម្មវត្ថុ៖ សំណើសុំការបកប្រែ") ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥។

[7] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[8] ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128។

[9] សំណើរបស់ មាស មុត សុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D129។

មេធាវីការពារក្តីបានដាក់សំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤។ ទោះបីមេធាវីការពារក្តីបានស្នើថា ឯកសារនេះគួរត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈក៏ដោយ ក៏ឯកសារនេះត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសម្ងាត់។

៤. នៅថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលតបទៅនឹងសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួន ចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤។ ទោះបីមេធាវីការពារក្តីបានស្នើថា ឯកសារនេះគួរត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈក៏ដោយ ក៏ឯកសារនេះត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសម្ងាត់។

៥. នៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាបង្គាប់ឱ្យនាំខ្លួនថ្មីមួយសម្រាប់លោក មាស មុត[10]។ ឯកសារនេះត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសម្ងាត់។

៦. នៅថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានដាក់សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ ទោះបីមេធាវីការពារក្តីបានស្នើសុំថា ឯកសារនេះគួរត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈក៏ដោយ តែឯកសារនេះត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសម្ងាត់។

៧. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាសម្រេចលើសំណើសុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ[11]។ គាត់បានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈចំពោះសំណើសុំការពិចារណាចំនួន ៣៩ ក្នុងចំណោមសំណើសុំការពិចារណាទាំងអស់របស់មេធាវីការពារក្តី រួមទាំងឯកសារពាក់ព័ន្ធបន្ថែមទៀតចំនួន ៦៣ ដែលគាត់យល់ឃើញថា

[10] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ C2។

[11] ដីកាសម្រេចលើសំណើរបស់ មាស មុត សុំធ្វើចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាឯកសារសាធារណៈ ដោយមានឧបសម្ព័ន្ធ ក និង ខ ជាឯកសារសាធារណៈ និង ឧបសម្ព័ន្ធ គ ជាឯកសារសម្ងាត់ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ("ដីកាសម្រេចលើការចាត់ចំណាត់ថ្នាក់ឡើងវិញ") ឯកសារ D129/1។

ចាំបាច់សម្រាប់ឱ្យសាធារណជនអាច "ពិនិត្យមើលឯកសារតាមខ្លឹមសារពេញលេញ និង ត្រឹមត្រូវ ដែលអាចដាក់បានតាមរយៈដីកាសម្រេចនេះ"[12]។ ឯកសារនានាដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារជាសាធារណៈ រួមមាន៖

ក. ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ដែលត្រូវបានផ្ញើទៅឱ្យលោក មាស មុត និង សហមេធាវីរបស់គាត់ នៅខែវិច្ឆិកា ឆ្នាំ ២០១៤ និង លិខិតប្រាស្រ័យទាក់ទងដែលពាក់ព័ន្ធ រួមទាំងការជូនដំណឹងរបស់លោក មាស មុត ស្តីពីការមិនអនុវត្តតាមដីកាកោះ[13]។

ខ. ដីកាបង្គាប់ឱ្យនាំខ្លួនចេញ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤[14] និង

គ. ដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[15]។

## II. ច្បាប់ និង ទន្លឹករណ៍

៨. លោក មាស មុត មានសិទ្ធិជាសារវ័ន្តក្នុងការទទួលបានដំណើរការជំនុំជម្រះក្តី ដោយតម្លាភាព

---

[12] *ដូចខាងលើ* កថាខណ្ឌ ១៥។

[13] ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ កំណត់ហេតុនៃការប្រគល់ដីកាកោះ មាស មុត សម្រាប់ការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A66/1។ ដីកាកោះសហមេធាវីរបស់ មាស មុត សម្រាប់ការបង្ហាញខ្លួនលើកដំបូងរបស់ មាស មុត ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A67។ សេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1។ សេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1.1។ សេចក្តីជូនដំណឹងដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1/1។ សេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមក្នុងការបង្ហាញខ្លួនបឋមដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/2។ ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមក្នុងការបង្ហាញខ្លួនបឋមដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/2/1។ ពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឱ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឱ្យបង្ហាញខ្លួនបឋម ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A77។ សេចក្តីជូនដំណឹងរបស់ មាស មុត អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត Harmon នូវពាក្យសុំរបស់គាត់ សុំប្តឹងអង្គបុរេជំនុំជម្រះឱ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឱ្យបង្ហាញខ្លួនបឋម ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ A77/1/1។

[14] ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ C1។

[15] ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128។

យុត្តិធម៌ និង សាធារណៈ ដែលត្រូវបានទទួលស្គាល់ និង ការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា[16] កិច្ចព្រមព្រៀង[17] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[18] វិធាន ២១(១) និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ[19]។ ខណៈដែលមានការតម្រូវការរក្សាការសម្ងាត់នៅក្នុងកិច្ចស៊ើបសួរ[20] សេចក្តីត្រូវការនេះត្រូវតែមានតុល្យភាពជាមួយនឹងប្រយោជន៍យុត្តិធម៌[21] និង តម្រូវការឱ្យសាធារណជនបានទទួលព័ត៌មាន និង យល់ដឹងអំពីកិច្ចដំណើរការនីតិវិធី[22]។ ចំពោះការដកស្រង់ពីច្បាប់ និង នីតិវិធីដែលអនុវត្តទៅលើសំណើសុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ លោក មាស មុត សូមបញ្ជូលដោយយោងកថាខណ្ឌ ១ ដល់ កថាខណ្ឌ ៥ នៃសំណើសុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ។

៩. សំណើរបស់លោក មាស មុត សុំទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ និង ការឆ្លើយតបដែលពាក់ព័ន្ធរបស់ខ្លួន មិនត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ ដោយសហចៅក្រមស៊ើបអង្កេត Harmon នៅក្នុងដីកាសម្រេចលើការចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញឡើយ ពីព្រោះឯកសារទាំងនោះមិនត្រូវបានបញ្ជូលក្នុងសំណើសុំឱ្យចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ ដោយត្រូវបានដាក់ក្រោយសំណើនេះ។ យ៉ាងណាក្តី ដូចទៅនឹងឯកសារដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញផ្សេងទៀតដែរ ឯកសារទាំងនេះអាចត្រូវបានចាត់ចំណាត់

[16] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មដោយក្រមចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រូវបានប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាផ្សេងៗទៀតពីជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាពជាតិនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩។

[17] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

[18] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

[19] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ត្រូវបានអនុម័ត និង បើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិកដោយសេចក្តីសម្រេចរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិលេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ អនុលោមតាមមាត្រា ៤៩។

[20] *សូមមើល* វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក.។

[21] *សូមមើល* មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារ។

[22] *សូមមើល* មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង។

ថ្នាក់ឯកសារឡើងវិញជាសាធារណៈ ដោយមិនប៉ះពាល់ដល់លក្ខណៈសម្ងាត់ ឬ សុចរិតភាពនៃកិច្ចស៊ើបសួរឡើយ។ ឯកសារទាំងនេះទាក់ទងនឹងឯកសារនានា ដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាឯកសារសាធារណៈ រួមទាំងដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដីកាកោះមុនៗ និង ដីកាសម្រេចបន្ទាប់ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*។ ឯកសារទាំងនេះមិនមានព័ត៌មានបន្ថែមណាមួយ ដែលត្រូវរក្សាជាការសម្ងាត់ទេ។

១០. ឯកសារដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ បានក្លាយជាឯកសារសាធារណៈ "ដើម្បីឱ្យសាធារណជនអាចពិនិត្យមើលឯកសារ... តាមខ្លឹមសារពេញលេញ និង ត្រឹមត្រូវ..."[23]។ សំណើរបស់លោក មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ និង ការឆ្លើយតបដែលជាប់ពាក់ព័ន្ធ *ត្រូវតែ* យកមកចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញដែរ បើមិនដូច្នោះទេ សាធារណជន *នឹងមិន* ទទួលបានខ្លឹមសារពេញលេញ និង ត្រឹមត្រូវអំពីឯកសារនានាដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញនាពេលថ្មីៗនេះនោះទេ។

១១. ទោះបីដីកាបង្គាប់ឱ្យនាំខ្លួនថ្មី ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ នៅតែជាការសម្ងាត់ក៏ដោយ ក៏ឯកសារនេះ និង សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដើម្បីរង់ចាំសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ ត្រូវតែយកមកចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ។ នាពេលថ្មីៗនេះ មានចំណាប់អារម្មណ៍ជាច្រើនពីសំណាក់សារព័ត៌មានជុំវិញឯកសារនានាដែលត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញនាពេលថ្មីៗនេះ[24]។ ការខកខានមិនបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញទៅលើឯកសារដែលជាប់ពាក់ព័ន្ធ *ទាំងអស់* បណ្តាលឱ្យមានការភ័ន្តច្រឡំ និង ទទួលបានព័ត៌មានខុស។ ជាឧទាហរណ៍ នៅក្នុងអត្ថបទមួយចេញផ្សាយថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥ នៅក្នុងកាសែតខេមបូឌាដេលី មានការពិភាក្សាពីដីកាបង្គាប់ឱ្យនាំខ្លួន

[23] កថាខណ្ឌ ១៥ នៃដីកាសម្រេចលើការចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ។

[24] *សូមមើល ឧទាហរណ៍* Holly Robertson និង Khuon Narim *រដ្ឋាភិបាលមិនអើពើនឹងដីកាបង្គាប់ឱ្យនាំខ្លួនឧក្រិដ្ឋជនសង្គ្រាមដែលត្រូវបានចោទប្រកាន់ (Gov't Ignored Arrest Warrant for Accused War Criminal)* កាសែតខេមបូឌាដេលី ចេញផ្សាយថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥។ Holly Robertson *អង្គការសហប្រជាជាតិពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធនឹង មាស មុត (UN to Review Documents Relating to Meas Muth)* កាសែតខេមបូឌាដេលី ចេញផ្សាយថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥។

ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដោយបានដកស្រង់ប្រសាសន៍របស់ប្រធានសន្តិសុខនៅ អ.វ.ត.ក. ដែលអះអាងថា គាត់ទើបតែបានទទួលដីកាបង្គាប់ឱ្យនាំខ្លួននេះ "នៅសប្តាហ៍មុន"[25]។ វាទំនងណាស់ថា ប្រធានសន្តិសុខនៅ អ.វ.ត.ក. កំពុងនិយាយពីដីកាបង្គាប់ឱ្យនាំខ្លួនថ្មី ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ ប៉ុន្តែប្រសិនបើសាធារណជនមិនបានដឹងថា ដីកាបង្គាប់ឱ្យនាំខ្លួនលើកទីពីរនេះត្រូវបានចេញ សាធារណជនមួយចំនួនអាចឈានទៅរកការសន្និដ្ឋានថា ប្រធានសន្តិសុខនៅ អ.វ.ត.ក. នេះ កំពុងនិយាយកុហកហើយ។

១២. នាពេលនេះ ដែលថា ឯកសារនានាដែលត្រូវចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ កំពុងត្រូវបានយកមកពិភាក្សានៅក្នុងសារព័ត៌មាន សូម្បីតែ អង្គការសហប្រជាជាតិក៏កំពុង "ពិនិត្យ" ទៅលើឯកសារទាំងនោះដែរ[26]។ ដើម្បីលើកកម្ពស់តម្លាភាព និង ធានាឱ្យបានថា កំណត់ហេតុពេញលេញ និងគ្រប់ជ្រុងជ្រោយ អាចរកបានសម្រាប់យកមកពិនិត្យនោះ ដីកាបង្គាប់ឱ្យនាំខ្លួនថ្មី ចុះថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៥ និង សំណើសុំការពិចារណា *ទាំងអស់* របស់មេធាវីការពារក្តី ដែលបានយោងក្នុងសំណើនេះ (សំណើសុំការពិចារណាទាំងឡាយដែលបានដាក់រួចហើយ និង សំណើសុំការពិចារណាដែលពាក់ព័ន្ធ ត្រូវបានដាក់នាពេលខាងមុខ) ត្រូវតែចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ។

១៣. តម្លាភាពក៏ចាំបាច់ផងដែរ ពីព្រោះ សាធារណជនអាចមានការយល់ច្រឡំចំពោះប្រតិកម្មរបស់លោក មាស មុត ទៅនឹងព្រឹត្តិការណ៍នាពេលថ្មីៗ ដោយសន្និដ្ឋានថា លោក មាស មុត មិនទទួលស្គាល់សមត្ថកិច្ចរបស់ អ.វ.ត.ក.។ តាមការពិត លោក មាស មុត បានបំពេញកិច្ចតាមរយៈសហមេធាវីរបស់គាត់ ដោយដាក់សំណើសុំការពិចារណា អនុលោមទៅតាមនីតិវិធីនានានៅ អ.វ.ត.ក.។ សាធារណជននឹងយល់ដឹងអំពីបញ្ហានេះកាន់តែប្រសើរជាងមុន ប្រសិនបើឯកសារ

---

[25] Holly Robertson និង Khuon Narim *រដ្ឋាភិបាលព្រងើយនឹងដីកាបង្គាប់ឱ្យនាំខ្លួនឧក្រិដ្ឋជនសង្គ្រាមជាប់ចោទ (Gov't Ignored Arrest Warrant for Accused War Criminal)* កាសែតខេមបូឌាដេលី ចេញផ្សាយថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥។

[26] Holly Robertson *អង្គការសហប្រជាជាតិនឹងពិនិត្យមើលឯកសារទាក់ទងលោក មាស មុត (UN to Review Documents Relating to Meas Muth)* កាសែតខេមបូឌាដេលី ចេញផ្សាយថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥៖ "អង្គការសហប្រជាជាតិមានគម្រោង "ពិនិត្យ" ឯកសារប្រកាសជាចំហថ្មីៗនេះជាច្រើន ដែលបង្ហាញថា នគរបាលយុត្តិធម៌មិនយកចិត្តទុកដាក់នឹងដីកាបង្គាប់ឱ្យនាំខ្លួនមេបញ្ជាការកងទ័ពជើងទឹកខ្មែរក្រហម និង បានចោទប្រកាន់លោក មាស មុត ថាជាឧក្រិដ្ឋជនសង្គ្រាម យោងតាមអ្នកជំនាញពិសេសរបស់ អ.ស.ប. នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)"។

ដែលបានស្នើឡើង *ទាំងអស់* ត្រូវបានចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសាធារណៈ។ មេធាវីការពារក្តីមិនចាត់ទុកថា ការកោសលុបគឺចាំបាច់នាពេលនេះទេ ប៉ុន្តែប្រសិនបើសំណើសុំការពិចារណាពាក់ព័ន្ធនានាដែលនឹងត្រូវដាក់នៅពេលខាងមុខ មានព័ត៌មានដែលត្រូវរក្សាជាការសម្ងាត់នោះ ព័ត៌មាននោះអាចត្រូវបានកោសលុបយ៉ាងងាយ។

**អាស្រ័យហេតុនេះ** ដោយសារមានសំអាងហេតុទាំងអស់ដែលបានជម្រាបជូនខាងលើ មេធាវីការពារក្តី សូមគោរពស្នើសុំសហចៅក្រមស៊ើបអង្កេតមេត្តា៖

ក. **ចាត់ចំណាត់ថ្នាក់ឯកសារឡើងវិញ** ជាសាធារណៈចំពោះសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលតបទៅនឹងសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួន ដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ និង សំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ដែលចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត Harmon ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ និង

ខ. **ចាត់ចំណាត់ថ្នាក់ឯកសារ** ជាសាធារណៈចំពោះសំណើសុំការពិចារណាទាក់ទងនានាដែលនឹងត្រូវដាក់នាពេលខាងមុខ។

សូមទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **២៦** ខែ **មិថុនា** ឆ្នាំ **២០១៥**

សហមេធាវីការពារក្តីលោក មាស មុត

| អាង ឧត្តម | Michael G. KARNAVAS |
| --- | --- |